**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្ដីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
លេខៈ .០៤៤/២២......អអរ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និង ទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តរតនគិរី"

ព្រឹកថ្ងៃទី២៧ ខែមករា ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តរតនគិរី»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ណាប់ ប៊ុនហេង ប្រធានក្រុមប្រឹក្សាខេត្តរតនគិរី**
- **លោក ឌុន ពៅ ចៅសង្កាត់កាចាញ ក្រុងបានលុង**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបង្ហាញសាធារណជនឱ្យបានយល់ច្បាស់ពីយន្តការប្រជាធិបតេយ្យថ្នាក់ក្រោមជាតិជាប្រវត្តិសាស្ត្រកម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលរដ្ឋបាលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឃុំ-សង្កាត់។

## I. សេចក្តីផ្តើម

ខេត្តរតនគិរី ស្ថិតនៅភាគឦសាន្ត នៃព្រះរាជាណាចក្រកម្ពុជា មានផ្ទៃដីសរុប ១០.៧៨២ គីឡូម៉ែត្រក្រឡា រដ្ឋបាលដែនដីត្រូវបានចែកជា ១ក្រុង និង៨ ស្រុក ៤៦ឃុំ ៤សង្កាត់ និង២៤៣ភូមិ មានប្រជាជនសរុបចំនួន ២០៨.៦៨៦នាក់ ស្ត្រី ១០២.៨៩៦នាក់ មាន៤៩.៥៥៥ គ្រួសារ ដង់ស៊ីតេប្រជាពលរដ្ឋ១៩នាក់/គម២ និងមានជនជាតិដើមភាគតិច ៨អម្បូរ ស្មើនឹង ៥៨% នៃប្រជាជនសរុបទូទាំងខេត្ត។ ប្រជាពលរដ្ឋ ៨២%ប្រកបរបបកសិកម្ម ក្រៅពីនេះមានការងារសិប្បកម្ម សេវាកម្ម ពាណិជ្ជកម្ម និងការងារផ្សេងៗទៀត ដែលជាមូលដ្ឋានក្នុងការលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃ។

## II. វឌ្ឍនភាពការងារ

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានខិតខំអនុវត្តមុខងារ ការកិច្ច និងធនធានដែលបានប្រគល់ និងផ្ទេរមកឱ្យក្រុមប្រឹក្សាខេត្ត ស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយបានចូលរួមក្នុងកម្មវិធី វេទិកា សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំនានា ក្នុងខេត្តសរុបចំនួន ៣៦៤លើក និងចូលរួមកម្មវិធីផ្សេងៗ ក្រៅខេត្ត ចំនួន ១០៤លើក។ លើសពីនេះ ក៏បានជម្រុញ និងត្រួតពិនិត្យលើការអនុវត្តសកម្មភាពគម្រោងនានាដែលបានអនុម័ត រួមមាន៖

- គម្រោងសាងសង់អគាររដ្ឋបាលស្រុកទំហំ ៨៥៦ម៉ែត្រការ៉េ ស្រុកតាវែង និងស្រុកអណ្តូងមាស ដែលមានកម្ពស់២ជាន់។
- គម្រោងសាងសង់អគារច្រកចេញចូលតែមួយជាន់ផ្ទាល់ដីស្រុកលំផាត់ ទំហំ ២២០ម៉ែត្រការ៉េ។
- គម្រោងស្ថាបនាស្ពានដែកបេឡេ ០១កន្លែងប្រវែង ៥៦ម៉ែត្រ ទទឹង ០៤ម៉ែត្រ
- គម្រោងកប់លូមូលបេតុងអាម៉េ រៀបស្ទួរបេតុង ចាក់ដីបំពេញចិញ្ចើមផ្លូវ ការរៀបការ៉ូឡូតាមចិញ្ចើមផ្លូវ ការរៀបចំក្រាលការ៉ូ ការ៉ូឡូបរិវេណសាលាខេត្ត និងការរៀបចំបង្គោលភ្លើងបំភ្លឺសាធារណៈនិងជួសជុលអំពូលភ្លើងLED នៅតាមបណ្តោយផ្លូវនានាក្នុង និងផ្លូវជុំវិញផ្សារក្រុងបានលុង
- គម្រោងស្ថាបនាផ្លូវកៅស៊ូ DBST និងប្រភេទ AC លើកំណាត់ផ្លូវមួយចំនួនក្នុងក្រុងបានលុង។

### ❖ សង្កាត់កាចាញ ក្រុងបានលុង

វឌ្ឍនភាពសំខាន់ៗ ដែលក្រុមប្រឹក្សាសង្កាត់សម្រេចបានរួមមាន៖

- បានអនុវត្តនូវគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព, រៀបចំសណ្តាប់ធ្នាប់, ការពារសន្តិសុខជូនប្រជាពលរដ្ឋ និងមានការដោះស្រាយ សម្របសម្រួលបណ្តឹងជូនប្រជាពលរដ្ឋ។
- បានបង្ក្រាបបទល្មើស ដូចជា ល្បែងស៊ីសង គ្រឿងញៀន អំពើលួចឆក់ប្លន់ គ្រោះថ្នាក់ចរាចរ។
- បានរៀបចំហេដ្ឋារចនាសម្ព័ន្ធក្នុងឃុំរួមមាន សាងសង់ផ្លូវបេតុង ១៦០២ម ផ្លូវគ្រួសក្រហម ៤ ០០០ម ជួសជុលផ្លូវក្រាលគ្រួស ដាក់លូតាមដងផ្លូវ និងប្រឡាយទឹក ជីកអណ្តូងទឹកស្អាត ជីកស្រះសហគមន៍ ដើម្បីតម្រូវការរបស់ប្រជាពលរដ្ឋ។
- បានឧបត្ថម្ភដល់គ្រួសារក្រីក្រ ស្ត្រីមានផ្ទៃពោះ កុមារ ចាស់ជរា និងបានចុះផ្សព្វផ្សាយអំពីសុខភាពអនាម័យជូនប្រជាពលរដ្ឋ។
- បានចុះផ្សព្វផ្សាយអំពីការណែនាំរបស់រាជរដ្ឋាភិបាល សារអប់រំសុខភាពរបស់ក្រសួងសុខាភិបាល ក្នុងការប្រឆាំងនឹងជំងឺកូវីដ-១៩ ព្រមទាំងបានចែកម៉ាស់ជូនប្រជាពលរដ្ឋ។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- ផ្តល់យោបល់ និងកំណត់ទិសដៅខេត្តក្នុងការពង្រឹកថាមពលអគ្គីសនី និងទឹកស្អាត។
- ជំរុញការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំដើម្បីធានាបាននូវការគ្រប់គ្រងប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ចូលរួមទប់ស្កាត់បញ្ហាទំនាស់ដីធ្លី។
- ជំរុញការផ្តល់សេវាសាធារណៈ និងសេវារដ្ឋបាលជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា តាមរយៈការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយដើម្បីបង្វិតសេវាសាធារណៈឱ្យគៀកនឹងប្រជាពលរដ្ឋមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។
- បន្តការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព
- បន្តការគាំទ្រយន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។
- បន្តពង្រឹងគោលនយោបាយរៀបចំផែនការអភិវឌ្ឍ និងការកសាងកម្មវិធីវិនិយោគខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ ឱ្យមានសង្គតិភាព និងការរៀបចំយុទ្ធសាស្ត្រថវិកា ឱ្យសមស្របទៅតាមតម្រូវការក្នុងការអភិវឌ្ឍ។
- បន្តចូលរួមក្នុងការប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ចូលរួមផ្សព្វផ្សាយអប់រំណែនាំ ប្រជាពលរដ្ឋនៅមូលដ្ឋានតាមសារអប់រំណែនាំរបស់ក្រសួងសុខាភិបាល។

### ❖ សង្កាត់កាចាញ ក្រុងបានលុង

- បន្តជួសជុល និងកសាងហេដ្ឋារចនាសម្ព័ន្ធតាមបណ្តាភូមិ
- បន្តជំរុញប្រជាពលរដ្ឋឱ្យខិតខំពង្រីកផ្ទៃដីដាំដុះ និងមុខរបរផ្សេងៗ
- បន្តការខិតខំពង្រឹងការអនុវត្តគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព និងពង្រឹងសុខសណ្តាប់ ធ្នាប់សាធារណៈ និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- បន្តអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋក្រីក្រ
- ខិតខំគៀងគរអង្គការដៃគូ អ្នកវិនិយោគ និងសប្បុរសជនជិតឆ្ងាយ ដើម្បីចូលរួមអភិវឌ្ឍន៍ភូមិឃុំឱ្យមានភាពរីកចម្រើន។

- បន្តចូលរួមសកម្មភាពនានាក្នុងការប្រយុទ្ធនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ពិសេសបន្តអប់រំ និងណែនាំដល់ប្រជាពលរដ្ឋឱ្យអនុវត្តវិធានការ ៣កុំ និង ៣ការពារ។

## IV. សម្គាល់

នៅក្នុងសន្និសីទសារព័ត៌មាននេះ ទទួលបានសំណួរពីអ្នកសារព័ត៌មាន និងការពន្យល់បកស្រាយពីវាគ្មិនដូចខាងក្រោម៖

*១. តើរហូតមកដល់ពេលនេះ មានសក្តានុពលអ្វីខ្លះចំពោះផលដំណាំក្នុងខេត្តរតនៈគីរី ?*

ចំពោះខេត្តរតនៈគីរី សម្បូរទៅដោយដីដែលមានជីវជាតិ (ដីក្រហម) ងាយស្រួលដល់ប្រជាជនក្នុងខេត្តអាចធ្វើដំណាំ និងទទួលបានផលច្រើន ដោយការធ្វើកសិឧស្សាហកម្ម និងកសិកម្មដោយលក្ខណៈគ្រួសារ និងក្រុមហ៊ុនវិនិយោគ មានដូចជា កៅស៊ូ ចន្ទី ដំឡូងមី និងចេកជាដើម។ សព្វថ្ងៃនេះ ដំណាំដែលនាំចេញច្រើនជាងគេគឺ ដំឡូងមី និងចេក ដែលទទួលបានតម្លៃខ្ពស់គួរឱ្យកត់សម្គាល់។

*២. តើបងប្អូនដែលជាជនជាតិដើមភាគតិច បានប្តូរទម្លាប់យ៉ាងណាហើយពីការធ្វើកសិកម្មបែបបុរាណទៅបែបទំនើបដែរឬទេ ?*

សព្វថ្ងៃនេះបងប្អូនជនជាតិភាគតិច មានការរីកចម្រើនគ្រាន់បើពាក់ព័ន្ធនឹងការធ្វើចម្ការ ដាំដុះដោយប្រើគោយន្ត ជំនួសឱ្យឧបករណ៍បុរាណផ្សេងៗ ដោយពួកគេបានយល់ដឹងពីរបៀបការប្រើប្រាស់តាមក្រុមហ៊ុន ប៉ុន្តែនៅតែមានជនជាតិភាគតិចចំនួនតិចតួច នៅតែមិនទាន់យល់ដឹងពីរបៀបដាំដុះបែបទំនើប ហើយបន្តធ្វើបែបប្រពៃណីបុរាណរបស់ពួកគាត់។

*២. តើវិស័យសុខាភិបាលក្នុងខេត្តមានបញ្ហាប្រឈមអ្វីខ្លះ ? ហើយមានតម្រូវការមន្ត្រីយ៉ាងទៀត ដើម្បីបម្រើសេវាសុខាភិបាលឱ្យបានទាន់ពេលវេលា ?*

ក្នុងស្ថានភាពបច្ចុប្បន្ន មន្ទីរសុខាភិបាលនៅមានកង្វះខាតមន្ត្រីសុខាភិបាលចំនួន ៥ភាគរយក្នុងការបម្រើការងារក្នុងមណ្ឌលសុខភាពចំនួន ៣០ និងមន្ទីរពេទ្យបង្អែកចំនួន ២។ ប៉ុន្តែមន្ទីរសុខាភិបាលមានមហិច្ឆតាក្នុងការពង្រីកមូលដ្ឋានសុខាភិបាល ដើម្បីគ្របដណ្តប់ជាសាកល ផ្តល់សេវាសុខាភិបាលដល់ប្រជាជនបានគ្រប់ទីកន្លែង ប្រកបដោយសុវត្ថិភាព និងងាយស្រួល។

*៣. តើស្ថានភាពរស់នៅរបស់ជនជាតិដើមភាគតិច បច្ចុប្បន្នមានការប្រែប្រួលយ៉ាងណាខ្លះ ?*

មកទល់ពេលបច្ចុប្បន្នស្ថានភាពរស់នៅរបស់ប្រជាជនពលរដ្ឋក្នុងមូលដ្ឋានមានការប្រែប្រួលច្រើន រាប់ទាំងជីវភាពមានភាពល្អប្រសើរ ទាំងទំនៀមទម្លាប់ប្រពៃណី ការរស់នៅ ការហូបចុកប្រចាំថ្ងៃរបស់ជនជាតិដើមភាគតិច ជាទូទៅបានប្តូរមកដូចប្រជាជនតំបន់កណ្តាល រួមទាំងបានអនុវត្តតាមច្បាប់ដែលរដ្ឋកំណត់បានល្អប្រសើរ។

*៤. តើមន្ទីរទេសចរណ៍មានចំណាត់ការយ៉ាងណា ក្នុងការគ្រប់គ្រងសេវាកម្មសម្រាប់វិស័យទេសចរណ៍ ?*

រដ្ឋបាលខេត្ត បានបង្កើតគណៈកម្មការអភិវឌ្ឍវិស័យទេសចរណ៍ខេត្ត ដែលមានឯកឧត្តមអភិបាលខេត្តជាប្រធាន ដោយមានអង្គភាពក្រោមចំណុះចំនួន ២៥ ដើម្បីសម្របសម្រួលការងារ និងអនុវត្តវិធានរបស់រាជរដ្ឋាភិបាល និងវិធានសន្តិសុខរបស់ភ្ញៀវទេសចរ ដែលបានទៅកម្សាន្តក្នុងខេត្ត។ ជាមួយគ្នានេះ មន្ទីរទេសចណ៍ខេត្ត តែងជួបប្រជុំពិភាក្សាជាមួយអ្នកផ្តល់សេវាកម្មទេសចរណ៍ ដើម្បីរកដំណោះស្រាយ និងរក្សាតម្លៃសេវាមិនឱ្យឡើងខ្ពស់ហួសហេតុ ក្នុងពេលបុណ្យទាន ដែលមានទេសចរមកច្រើន។

*៥. តើស្ថានភាពវិស័យអប់រំក្នុងខេត្តមានការវិវត្តយ៉ាងណា ? ជួបបញ្ហាប្រឈមអ្វីខ្លះ ?*

ក្នុងខេត្តរតនគិរីមានសិស្សចូលរៀនប្រមាណជាង ៦ម៉ឺននាក់ ស្មើនឹង៩៦ភាគរយ នៃកុមារគ្រប់អាយុចូលរៀនក្នុងខេត្ត។ សម្រាប់ឆ្នាំសិក្សា ២០២០-២០២១ នេះ មានបេក្ខជនប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ៨៧២នាក់ ក្នុងនោះស្រី៤២០នាក់ ស្មើនឹង៧៥.៨៥ភាគរយ (និទ្ទេស A ៩នាក់) ដែលជាអត្រាមួយខ្ពស់ធៀបនឹងបណ្តាខេត្តនានា។ ជាមួយគ្នានេះ ក៏បានសាលារៀនមួយចំនួន មានសិស្ស១០០ភាគរយ បានប្រឡងជាប់ ហើយទទួលបានចំណាត់ថ្នាក់ជាសាលាគម្រូ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា រួមនឹងដៃគូរអភិវឌ្ឍបរទេសជាច្រើន។ ជាមធ្យមសិស្សដែលបោះបង់ការសិក្សាមានប្រមាណ ៨ភាគរយ ដោយមូលហេតុទំនៀមទម្លាប់ (ក្មេងស្រីត្រូវរៀបការវ័យក្មេង ការប្រើប្រាស់ភាសា) បញ្ហាចំណាក ចំណូលស្រុក។

*៦. តើវិស័យពាណិជ្ជកម្មក្នុងខេត្តមានការវិវត្តដូចម្តេច ?*

ខេត្តរតនគិរីបាននាំចេញនូវផលិតផលជាច្រើន រួមមានកៅស៊ូក្រែប ចេក ខ្នុរ ស្វាយ ម្នាស់ ស្រការនាគ ក្រូច គ្រាប់ស្វាយចន្ទី ដំឡូងមី សណ្តែកសៀង ម្រេច លូ និងថ្មម៉ាប ដែលមានទំហំទឹកប្រាក់នៃការនាំចេញប្រមាណ ៥៤លានដុល្លារ សម្រាប់ឆ្នាំ២០២១។ ជាមួយគ្នានេះ ខេត្តក៏បាននាំចូលផលិតផលមួយចំនួនដូចជា ក្រដាសកាតុង ថង់ផ្លាស្ទិក ជ័រ ស្មោ ជីកសិកម្ម។

ថ្ងៃសុក្រ ១១រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២